# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៧

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៣

គ.ស. ១៩៤០

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្តីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៧

គណៈរដ្ឋមន្ត្រីនឹងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៣
គ.ស. ១៩៤០

# បញ្ជីរឿង

ទំព័រ


១ — និយាយអំពីអាវុធបរិរបស់ប្រទេសឥណ្ឌាសម័យបុរាណ . . . . . . . . . ៣

២ — អំពីពន្ធ (ក្នុងប្រទេសឥណ្ឌូស៊ីន) . . . . . . . . . . . . . . . ៥

៣ — អនាមយកថា របស់ទេមរង្សី (តមក) . . . . . . . . . . . . . . ៨

៤ — ច្បាប់សុភាសិត របស់អ្នកឧកញ៉ាវង្សាសារពេជ ឧង (តមក) . . . . . ១៣

៥ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . ១៧

៦ — រឿងព្រេងខ្មែរៈ «រឿងអាឡេវទី ២» របស់អ្នកឧកញ៉ាប្រាជ្ញាធិបតី យិន (តមក) . . . . . . . . . . . . . . . . . . . ២៤


## រូបក្រៅរឿង


ហ្លួងព្រះបាង — ក្បួនហែព្រះរាជទ្រព្យកំពុងហែចូលទៅវត្តធាតុដើម្បីស្រង់ព្រះពុទ្ធរូប . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages.

1° Quelques notes sur la civilisation de l'Inde antique........ 3

2° Causerie radiophonique de Radio-Saïgon au sujet de l'impôt. 5

3° ANĀMAYAKATHĀ par KHÉMARARANSĪ (suite)................ 8

4° Chbab SUBHĀSIT (Poème Khmèr) par Oknhā VONGSĀSARAPÉCH (NONG) (suite)................................ 13

5° Informations diverses.............................. 17

6° Conte populaire cambodgien inédit:

"Légende de ALÉV II" par Oknhā PRACHNHĀTHIBADEY (YIN) (suite)................................ 24


HORS TEXTES:


Luong - Prabang — Cortège Royale se rendant à la pagode pour la cérémonie de L'ABHISÉKA des statues du BOUDDHĀ. 1



ហ្លួងព្រះបាង – ក្បួនហែព្រះរាជទ្រព្យកំពុងហែចូលទៅកាន់វត្តនានា ដើម្បីស្រង់ព្រះពុទ្ធរូប ។

# អារ្យធម៌ប្រទេសឥណ្ឌា

កាលពីពុទ្ធសករាជ ១១៨៩ ដល់ ១១៩១ មានអ្នកធុតង្គជាតិចិនម្នាក់ឈ្មោះ ហ្វួន-ស្ទង់ ធ្វើដំណើរទៅមើលប្រទេសឥណ្ឌា ហើយបានទៅចងមេត្រីជិតស្និទ្ធក្នុងរាជសំណាក់នៃក្សត្រហាស៌ៈ ( Harsa ) មុនឡើងគ្រងរាជ្យបល្ល័ង្ក ក្សត្រអង្គនេះទ្រង់បានសាកសួរព្រះពោធិសត្វអវលោកិ-តេស្វរៈ ដោយទ្រង់ព្រះតម្រិះថា ទ្រង់នឹងបានទទួលជម្នូនយ៉ាងវិសេសអំពីព្រះពោធិសត្វអង្គនោះ ៗ មានព្រះភគិនីរបស់ក្សត្រអង្គនោះ ជាស្ត្រីដែលមានសតិបញ្ញាវាងវៃ យល់ច្បាស់ ចេះដឹងជ្រៅជ្រះក្នុងលទ្ធិពុទ្ធ-សាសនាប៉ែកខាងសម្មតិយរបស់ហីនយាន ៗ ឯព្រះភគិនីអង្គនោះទ្រង់ធ្វើការងារដ៏សំខាន់មួយដែលមានប្រយោជន៍ជាសាធារណៈ គឺបុណ្យហែព្រះពុទ្ធរូបមាស ១ អង្គ ៗ លោក ហ្វួន-ស្ទង់ ក៏បានចូលហែនឹងគេដែរ ៗ គ្រានោះ ក្សត្ររបស់ឥណ្ឌាពីរអង្គ ទ្រង់តែងព្រះអង្គដោយគ្រឿងសម្លៀកបំពាក់ដូចជារូបព្រះឥន្ទ្រ ក្សត្រ ១ អង្គទៀតតែងព្រះអង្គជាព្រះព្រហ្ម ហើយទ្រង់ឈរអមព្រះពុទ្ធរូបនោះ នៅខាងក្រោយក្បួនហែនោះ មានដំរីខ្នាតធំៗ ពីរផ្ទុកកញ្ឆើផ្កា ៗ ក្សត្រហាស៌ៈជាក្សត្រ ១ អង្គដែលទ្រង់ជ្រះថ្លានឹងព្រះពុទ្ធសាសនាយ៉ាងមាំមួន ទ្រង់ចាត់ឲ្យមានការសន្និបាតឡើង មានចំនួនព្រះភិក្ខុសង្ឃដល់ទៅ ៣.០០០ រូប មានលោកសង្ឃព្រាហ្មណ៍នឹងជៃនៈចំនួន ២.០០០ រូប ហើយស្តេចយាងចូលទៅ

កាន់ព្រះយាគៈ (ព្រះរាជកំន័?) ទើបទ្រង់ប្រជុំអស់លោកនោះដើម្បីទ្រង់ធ្វើទានជាព្រះរាជកុសល ។ ថ្ងៃទី ១ ទ្រង់ធ្វើសក្ការបូជាដល់ព្រះពុទ្ធ ថ្ងៃទី ២ ទ្រង់ធ្វើសក្ការបូជាដល់ព្រះអាទិត្យ ថ្ងៃទី ៣ ទ្រង់ធ្វើសក្ការបូជាព្រះឥស្សូរ ។ ទ្រង់ឲ្យសាងរោងទានសម្រាប់ចែកអាហារភោជននឹងគ្រឿងថ្នាំផ្សេងៗ ។ ការឲ្យទាននេះ តែងមានជានិច្ចមិនដែលខាន ។

លោក ហួន-ស្តង់ បានទទួលដំណឹងដែរ ក្នុងការដែលមានគេមកប៉ងប្រទូសរ៉ាយដល់ព្រះបាទហាសិៈ ។ ទ្រង់សួរអ្នកប្រទូសរ៉ាយដោយព្រះអង្គ លោក ចោរនោះឆ្លើយដាក់ពួកព្រាហ្មណ៍ដែលមានចិត្តប្រណែនឈ្នានីស ដែលទ្រង់ទំនុកបំរុងលោកសង្ឃពុទ្ធសាសនាច្រើនជាងពួកព្រាហ្មណ៍ ។

*
* *

នៅក្នុងខាងចុងឆ្នាំពុទ្ធសករាជ ១៥៨៥ នោះ មានគណៈអ្នកផ្សាយសាសនារបស់ឥណ្ឌាយ៉ាងល្បីល្បាញ ១ រូប លោកនេះឈ្មោះ អតីស បួសជាភិក្ខុកាលពីអាយុ ២៩ ដល់អាយុ ៥៩ ចេញទៅប្រទេសទីបេត៍ ហើយបានត្រាច់ចារិកទៅសព្វអន្លើ ។ បន្ទាប់ក្រោយលោកនេះមក ប្រទេសឥណ្ឌាមិនមានផ្សាយអារ្យធម៌ទៅប្រទេសទីបេត៍ទៀតឡើយ រវល់តែនឹងចម្បាំងដែលត្រូវច្បាំងតទល់នឹងមុស៊ុល្ម៉ានតាំងពីពុទ្ធសករាជ ១៧៦៣ ម្ល៉ោះហើយវត្តអារាមពុទ្ធសាសនា ក៏ត្រូវពួកមហាម៉ាត់កំទេចចោលទៅ ព្រះសង្ឃក៏ត្រូវចាប់ខ្លួនសម្លាប់ លទ្ធិពុទ្ធសាសនាក៏អន្តរាយអស់ទៅ ។

# អំពីពន្ធ

មន្ទីរវិទ្យុនានាប្រទេសមួយកន្លែង បាននិយាយបង្អាប់ទើបនឹងរួចថា នៅប្រទេសខ្មែរ ពន្ធសព្វសារពើនឹងឡើងទ្វេមួយជាពីរដើម្បីនឹងឲ្យទឹកប្រាក់ក្រសួងកាន់ប្រាក់ចំណូលចំណាយនៅនគរបារាំងសែសបានចម្រើនកើនឡើងទៀត ។

ពិតមែនតែឈ្មោះមន្ទីរវិទ្យុប៉ុណ្ណោះ ល្មមធ្វើឲ្យអ្នកស្តាប់ការនិយាយពោលផ្សាយដំណឹង មានចិត្តស្ទើរតែជឿតិចណាស់ ។ យើងត្រូវនិយាយឲ្យដឹងសេចក្តីជាក់ច្បាស់អំពីរឿងពន្ធខាងលើនេះខ្លះ ជាការមិនឥតប្រយោជន៍ទេ ។

មុនដំបូងគឺជាការពិតប្រាកដ ដែលប្រកែកមិនកើត គឺថាពន្ធផ្ទាល់ខ្លួនទាំងអស់ ដូចយ៉ាងពន្ធថ្លៃខ្លួនដាក់ឃ្លាំងប៊ុតសេសម្រាប់ប្រទេស ហើយសម្រាប់តែចាយក្នុងប្រទេសតែប៉ុណ្ណោះ ។ កាស៊ីអាករខ្លះ ហើយនឹងពន្ធអនុញ្ញាតក្រសួងគយការរងទាំងអស់ដាក់ឃ្លាំងប៊ុតសេរួមទូទៅ (budget-général) ហើយសម្រាប់បើកឲ្យប៊ុតសេប្រទេសឥណ្ឌូស៊ីនទាំងមូល ។ តែស្រុកចំណុះ ឬស្រុកនៅក្រោមអាណាព្យាបាលបារាំងសែស មិនដែលទទួលចេញសោហ៊ុយចំណាយដាច់ខាតរបស់នគរបារាំងសែសណាមួយសោះ លើកមួយតែចំណាយក្នុងការរបស់ស្រុកចំណុះនោះមួយ ៗ

រួចពីនេះមក ដំណើរជាពន្ធទាំងឡាយនឹងឡើងទ្វេមួយជាពីរនោះ ខុសទេ ។ នេះគឺជាសេចក្ដីភរកុហកដែលនាំឲ្យរវល់គិតខ្វល់ខ្វាយក្នុងគំនិត ។

អំពីកិច្ចការនៅក្នុងនគរបាកំងសែសនោះ ជាការស្រួលបួលធម្មតារបស់នគរដែលច្បាំងទើបនឹងរួច ដូចគ្រាដែលយើងកន្លងរួចមកហើយនេះ ។ រាជការរបស់មេសិក ( ប៉េតាំង ) បានបើកប្រាក់ទុកឲ្យចំណាយរាប់ប្រមាណរយៈកោដិត្រណោតរួចហើយ, បើគិតជាទឹកប្រាក់យើងត្រូវច្រើនរយៈកោដិរៀល សម្រាប់ជួសជុលឬសង់ផ្ទះសំបែងបាក់បែកសព្វសារ-ពើទាំងអស់ក្នុងទឹកដែនទទួលបាបគ្រោះដែលសត្រូវចូលមកបុកដណ្ដើមកំទេចគ្មានសល់ សង់ផ្ទះជាថ្មីរាប់ហ្មឺន, សង់ស្ពានរាប់រយ, ធ្វើផ្លូវថ្នល់ឬផ្លូវរទេះភ្លើងរាប់ហ្មឺនគីឡូម៉ែត្រ ។ អ្នកធ្វើការក្នុងការដូចរៀបរាប់ខាងលើនេះរាប់សែននាក់ ។ តាំងពីប៉ុន្មានខែមកហើយ ជំនួញតាមរទេះភ្លើងបានចាប់ដើរតាមធម្មតាឡើងវិញនៅនគរបាកំងសែស ។ គេបានធ្វើស្ពានបណ្ដោះអាសន្នជាច្រើន ដើម្បីឲ្យរទេះភ្លើងនឹងរថយន្តបរសិន ទំពាំងទឹងធ្វើស្ពានធំៗខ្លះជាថ្មីឡើងវិញ ។ ជំនួញតាមជើងកប៉ាល់បានដើរទៅមកនគរបាកំងសែស នឹងមហាប្រទេសចំណុះឡើងវិញ ។

មានរឿងមួយទៀតដែលយើងចង់និយាយសសោះអន្ទង គឺថានគរបាកំងសែសបានចាយប្រាក់អស់ច្រើនណាស់ក្នុងប៉ុន្មានឆ្នាំនេះ ដើម្បីនឹង

ឲ្យសេដ្ឋកិច្ចហើយនិងការខាងប្រជាគមរបស់មហាប្រទេសចំណុះបារាំងសែសបានកើនឡើងទៀត ។ ប្រាក់បង់ការឲ្យរាជការ ដែលបានយកមកធ្វើរទេះភ្លើងទាំងឡាយនៅប្រទេសឥណ្ឌូចិន ជាតិបារាំងសែសនៅនគរបារាំងសែសបានចុះឈ្មោះសុខចិត្តបង់ការប្រាក់ឲ្យរាជការច្រើនជាងគេ ។ សោហ៊ុយចំណាយក្នុងការទាហានសឹកនៅប្រទេសឥណ្ឌូចិនប៉ុតសើនគរបារាំងសែសចេញទាំងអស់ហើយ ប៉ុតសើប្រមែទូទៅរបស់ប្រទេសឥណ្ឌូ-ចិនទាំងមូល សង់មួយភាគតូចក្នុងការចំណាយទាំងអស់នេះ ។ សោហ៊ុយចំណាយក្នុងការថែរក្សាគាំពារកប៉ាល់ចម្បាំងរបស់ប្រទេសឥណ្ឌូចិននគរបារាំងសែសចេញទាំងអស់ ។ បើដូច្នោះគឺជាតិបារាំងសែសនៅនគរបារាំងសែសដែលបង់ពន្ធសព្វសារពើសំរាប់យកមករៀបចំស្រុកចំណុះបា-រាំងសែសឲ្យមានដំណើរថ្កើងឡើង ហើយជួយការពារសត្រូវឲ្យបានសេចក្តីសុខ ។ ប៉ុន្តែស្រុកចំណុះទាំងប៉ុន្មាននេះមិនដែលជួយចេញប្រាក់ឲ្យប៉ុត-សើនគរបារាំងសែសវិញទេ ។ នេះគឺនគរបារាំងសែសបានធ្វើរួចមកហើយ ។ ទីងធ្វើឲ្យអ្នកឯងកល់គ្នាតទៅទៀត ។

នៅសេចក្តីបញ្ចប់ ប្អូនអ្នកកល់គ្នាកុំស្តាប់សេចក្តីកុហករបស់ឃោសនា-ការផ្សាយដំណឹងរបស់ប្រទេសដទៃៗដែលសមតែស្អប់ខ្ពើមចៀសវាង ។

# អនាមយកថា

## ១. ស:

អ្នកប្រែនិងរៀបរៀង (តមក)

ដោយលំបាក ត្រូវតែដកទំពថយលើកត្រឡប់ទៅវិញ ដែលពេលមកនេះមានទុបមាយ៉ាងណា សេចក្ដីទុចមេមយ្យក៏មានទំនងដូចគ្នាដែរ ។

## ប្រជារាស្ត្រភ្ញាក់ផ្អើល

កាលបានដំណឹងថាសឹកសត្រូវលើកទ័ពចូលមកក្នុងខែត្រដែនហើយ ពួកប្រជារាស្ត្រក៏ភិតភ័យភ្ញាក់ផ្អើល នេះត្រូវនឹងពេលដែលចាប់ផ្ដើមកើតឡើងយ៉ាងស្រាល ៗ ក្នុងកាយ ៗ ក៏កើតកោលាហលឡើង អវយវៈផ្សេង ៗ ធ្វើការខុសប្រក្រតី ដឹងខ្លួនថាមិនស្រួលខ្លួន, មិនឃ្លានបាយ, ស្រៀវស្រាញ, ឈឺក្បាលជាដើម បើសិនបើកងកាយអាចទប់ទល់នឹងខ្មាំងសត្រូវត្រឹមប៉ុណ្ណោះបាន អាការកើតក៏ប្រាកដឡើងត្រឹមប៉ុណ្ណោះហើយសន្សឹម ៗ បាត់អស់ទៅ ត្រឡប់សះជាដូចប្រក្រតីវិញ ប៉ុន្តែមានជម្ងឺខ្លះទៀតស្រាប់តែចាប់កើតឡើងមានអាការឈឺធ្ងន់តែម្ដង ធ្វើឲ្យអ្នកជម្ងឺដួនដាបចុះមួយរំពេចមិនដឹងខ្លួនប្រាណក៏មាន ក្នុងកាយក៏កើតកោលាហលយ៉ាងខ្លាំងត្រាតែមានអាការសន្ធប់សន្ធិនឬដល់នូវសេចក្ដីស្លាប់ក៏មាន នេះមានទំនងដូចជាការកើតចលាចលបះបោរឡើងក្នុងនគរ មិនមែនត្រឹមតែធ្វើឲ្យប្រជារាស្ត្រមានសេចក្ដីភ្ញាក់ផ្អើលប៉ុណ្ណោះទេ ។

# អាការរបស់រោគ

មានអាការរោគបំពួកខ្លះធ្វើឲ្យអ្នកជម្ងឺឈឺជាប់ជាខ្លាំងមួយរំពេច ហើយទៅឡើងដល់ថ្នាក់ធ្ងន់បំផុត កាលបើមកដល់ថ្នាក់នេះហើយនៅតែមិនទាន់ស្លាប់ទេ ក៏នឹងបែរជាសះស្បើយឡើងវិញ គ្រាន់តែសះជាស្រឡះទៅ ៗ បើបែរជាដល់នូវសេចក្ដីស្លាប់វិញ ក៏គឺជាពួកបាក់តេរីដែលជាខ្លាំងសត្រូវនោះមានចំនួនច្រើនលើកទ័ពចូលរុករានញាំញីសម្លាប់កងទ័ពដែលតាំងទប់ទល់ការពារនោះគ្រាន់តែបាក់បែកខ្ទេចខ្ទីអស់ទៅ ឬមួយថាបើបែរជាមិនស្លាប់ត្រឡប់ជាធូរថយគ្រាន់បើឡើងវិញ ក៏គឺជាកងទ័ពបំផុតបម្រុងនោះយើងមានជ័យជំនះឡើងវិញ កងទ័ពខ្លាំងសត្រូវដកទ័ពថយពីស្រុកទៅអស់ ៗ បើសត្រូវមានកំឡាំងតិច អ្នកជម្ងឺក៏មានអាការឈឺតែបន្តិចៗសន្សឹមៗធ្វើឲ្យយើងមានពេលព្យាបាលបានដោយស្រួល ៗ

កាលបើសឹកសត្រូវដកទ័ពថយចេញទៅផុតពីខេត្តដែនរបស់យើង ហើយ យើងត្រូវតែព្យាយាមកសាងនឹងជួសជុលរបស់ដែលខូចខាតបាក់បែកទៅទាំងប៉ុន្មាននោះឲ្យល្អជាដូចដើមឡើងវិញ ៗ មានចួនកាលសឹកសត្រូវដែលដកទ័ពថយទៅវិញនោះបានធ្វើទ្រព្យសម្បត្តិនឹងស្បៀងអាហាររបស់យើងឲ្យវិនាសខូចខាតអស់ទៅ គ្រាន់តែយើងមានកំឡាំងថយខ្សោយពន់ពេកមិនអាចតាំងខ្លួននៅជាជាតិមួយដូចដើមវិញបានក៏មាន អ្នក

ដែលមានជម្ងឺធ្ងន់ៗហើយបានសះជាឡើងវិញថ្មីៗនោះ ក៏មានធុំទំនងដូចគ្នាដែរ អ្នកជម្ងឺធ្ងន់មានអាការថយខ្សោយកំឡាំងអស់ការឃ្លាតខ្លួនបួនកាលបែរជាស្លាប់ព្រោះហេតុនេះក៏សឹងមានខ្លះដែរ ។

## អំពីហេតុផ្សេងខាងក្រៅ

មានបួនកាលមិនមែនត្រឹមតែកើតរោគនោះមួយមុខប៉ុណ្ណោះទេ នៅមានហេតុផ្សេងខាងក្រៅបន្ថែមលើរោគនោះទៀត មានឧទាហរណ៍ដូចយើងឈឺគ្រុន ហើយមានខ្លះក្នុងត្រចៀក ឬក្អកពិការ ឬពោះដូងពិការ ឬមួយកើតរោគផ្តាសាយ ហើយក្លាយទៅជាកើតរោគស្អួតពិការថែមទៀត ។ល។ នេះកើតឡើង ពីព្រោះតែរាងកាយរបស់យើងទន់ខ្សោយកំឡាំង ទើបបណ្តាលឲ្យកើតរោគដទៃៗថែមជួនឡើងទៀត ។ រឿងនេះ មានឧទាហរណ៍ដូចជាយើងកំពុងធ្វើស្រែធម្មតាទឹកប្រទេស១ ក្នុងខណៈដែលស្រុកទេសមានកំឡាំងខ្សោយនោះ ស្រាប់តែមានប្រទេសជិតខាងដែលមិនត្រូវនឹងយើងចាំរកពេលចន្លោះនោះ រករឿងបង្កហេតុឡើង លើកពលចូលមកវាយថែមជួនជាពីរត្រួត ឬពុំនោះសោត កញ្ឆ្នាំរបស់យើងកើតបះបោរបោលាចលឡើង វាយដណ្តើមប្លន់យកទ្រព្យសម្បត្តិរបស់ប្រជាជនស្លូតត្រង់ជាដើម ។

# អំពីយុទ្ធវិធីរបស់ប៉ក់តេរី

ផ្លូវដែលបាក់តេរីចូលមកលុកលុយក្នុងកាយរបស់យើងបាននោះ មាន ៣ ផ្លូវ គឺ:

ក) លើកចូលមកតាមអាកាសដែលយើងដកដង្ហើម មានទំនងដូចសឹកសត្រូវដែលលើកចូលមកតាមយន្តហោះ ។

ខ) លើកចូលមកតាមទឹកនិងអាហារដែលយើងបរិភោគ មានទំនងដូចសត្រូវដែលលើកក្រុកចូលមកតាមផ្លូវទឹក ។

គ) វានាំគ្នាជ្រែកចូលទៅតាមសាច់ស្បែក នេះមានទំនងដូចជាសឹកសត្រូវដែលលើកទ័ពចូលមកតាមផ្លូវគោក ។

កាលដែលកងទ័ពបាក់តេរីលើកចូលទៅក្នុងកាយរបស់យើងបានដោយផ្លូវណាមួយហើយ វាតែងតែប្រឹងខ្លួននឹងត្រៀមវិធីការពារខ្លួនរបស់វាដូច្នេះ:

១) វាចាប់ផ្តើមបង្កើតពួកវាឡើងយ៉ាងរហ័សរួសរាន់ ដូចពោលមកហើយខាងដើមនេះ គឺថាវាបន្ថែមកំឡាំងវាឲ្យមានចំនួនច្រើនកើនឡើងសម្រាប់ប្រឹងខ្លួនតទល់នឹងយើង មានទំនងដូចជាសឹកសត្រូវកេណ្ឌពលប្រជុំពាហានចូលប្រចាំការតាមមុខក្រសួងខ្លួនរៀងខ្លួន ។

២) វាធ្វើថ្នាំពិសផ្សាយចេញជុំវិញខ្លួនវា មានទំនងដូចសឹកសត្រូវ

តាំងបន្ទាយជីកស្នាមភ្លោះ ហើយនាំកាំភ្លើងធំទៅតាំងទុកក្នុងទីផ្សេងៗ ដោយជុំវិញ បើសឹកសត្រូវលុកចូលទៅក្នុងបរិវេណនោះ គេនឹងតែត្រូវកំទេចដោយកាំភ្លើងធំមិនខាន ។

៣) វាព្រួសថ្នាំពិសឬបណ្តែតខ្លួនវាឲ្យអណ្តែតចូលទៅក្នុងលោហិត ហើយផ្សាយចេញទៅសព្វសរាង្គកាយរបស់យើង ដើម្បីធ្វើឲ្យអវយវៈនោះៗធ្វើការមិនបានស្រួលតាមមុខក្រសួងរបស់ខ្លួន ទាំងកំលាំងតស៊ូទប់ទល់ក៏ទន់ខ្សោយទៅ មានទំនងដូចជាសឹកសត្រូវបាញ់ប្រុះមកត្រូវស្រុកយើងដោយកាំភ្លើងធំ ឬដូចជាយន្តហោះរបស់សត្រូវហោះមកទម្លាក់គ្រាប់បែកធ្វើឲ្យទាហានភិតភ័យភ្ញាក់ផ្អើល ហើយពួកពស្រុកក៏ច្រួលច្រាល់ ។

៤) វានាំគ្នាចោមស៊ីស្បៀងអាហាររបស់យើង ដែលសម្រាប់ជប់លៀងកងកាយ ឬដណ្តើមយកស្បៀងអាហាររបស់យើងទៅ ធ្វើឲ្យយើងទន់ខ្សោយកំលាំងមិនអាចតទល់បានយូរតទៅមុខទៀត នេះមានទំនងដូចជាសឹកសត្រូវវាយកាត់ដណ្តើមយកស្បៀងអាហាររបស់យើងទៅ ។

នេះ

# ច្បាប់សុភាសិត

ប្រសើរពេកពិត ប្រែពីគាថា
បន្ទូលព្រះពុទ្ធ បំបាត់ទោសា
ឲ្យអស់ទាំងមហា- ជនផងត្រង់ត្រាប់ ។

និព្វានបច្ចយោ ហោតុ មេ ។

របស់

ឧកញ៉ាវង្សាសារពេជ្រ និង ជាងហ្វាងក្រុមរាជបណ្ឌិត

ក្នុងរាជ្យព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី

(ព្រះអង្គដួង) ។

(តមក)

៤០ — យោធជនោ អវក្ខិតោ មហាបេតាំ តំយោ គភ ជស្សុនទំ សត្តអស្សំ បញ្ចមដ្ឋាក ។ អដ្ឋកុញ្ជៈ ភក្ខោសៈ ទ្វេអាវុធា ទ្វេគរិយាយំ អវមង្គលា គយំ អសា- ធុតាំជនេ ។ ពាក្យនេះលោកថា ពុំឲ្យរកា នូវក្របីតែ មួយមានចង្រៃ ទុក្ខភ័យឯងឯង គោ ៣ សោតគេ ពុំឲ្យរកា ។ ឆ្ក៤ នូវក្ដែ ប្រាំមួយឯងឯង សេះប្រាំពីរណា ដំរីប្រាំបី អប្រិយ៍យសា ចុងសក់ បែកជា ពីរពុំប្រពៃ ។ ប្រពន្ធពីរណា ដាវពីរពុំជា សោតសឹងចង្រៃ អព្ទមង្គល អំពល់ទុក្ខភ័យ ពិតពុំប្រពៃ នៃអ្នកនោះណា ។

៤១ — ឧកាត្តយៈ កាដ្ឋំឃរៈ ហាដ្ឋកោកា កាសំឃ- វៈ ចកោតិលា មណ្ឌូជរិកា ឃរសិហោ ។ ធារធមិវិ- សាល វិសេសបរិបាល បរមត្ថសេដ្ឋោ កណ្ឌូបគន់គិត គំនិតអសោ ចិត្តមោះមោហោ ហេតុតិរច្ឆាន ។ កាលណាស្រោតទៅ ទំលើចុងស្មៅ ហើយអ្នកឯប្រាណ ដំណើរអញណា ដូចមហាហង្សបាន ឥតទីងហង្ស មាន អញតាំងបានហោង ។ ក្អែកសោតកាលក់ ហើរទៅទំនា ចុង បង្គោលផង អ្នកសំឡេងថា ឥតតាហើហោង មានអង្គអញស្អុង គា- ហើបក្សី ។ កង្កែបកាលណា ចេញពីរន្ធក យំហើយគិតខ្ញី អ្នកអង្គ ឯងអាច ដូចរាជសីហ៍ បរចេញអំពី គុហាសុវណ្ណា ។

៤២ – ឧលិទ្ទុសៈ ជជំមរៈ ឡូរកាតា ក្សត្រិអវិព្យាបណ្ឌិតា អាចរិយា សច្ចំមរណំ ។ ពាក្យពិតសារសត្យ សារសេចក្តីថា បរមសេដ្ឋ អ្នកណាពុំមាន ធនធានទ្រព្យ[១] ទុកស្មើមរណំ សេរូបឥតការ ។ ក្សត្រិបើមាន ដំនៀលដល់ប្រាណ សោតសឹងអសារ អសោចអាសៅ លោកហៅស្រីបស្រាល សូន្យសោះឥតការ ឥតកេរ្តិ៍ស្មើស្លាប់ ។ មួយនាអ្នកប្រាជ្ញ បណ្ឌិតឯងអាច ពុំឈ្លាសវៃឆាប់ អគ្គិឥតប្រាជ្ញា លោកថាស្មើស្លាប់ សោតសឹងទុនអាប់ អគ្គិជងនោះនៃ ។ មួយអគ្គអាចារ្យ ឥតស័ព្ទឥតសារ ឥតសិល្បសាស្ត្រសែយ ឥតមានពាក្យសត្យ ភ្លាំងភ្លាត់ហឫទ័យ ស្មោះស្មើក្សណក្ស័យ ដ្បិតចិត្តមោហោ ។

៤៣ – យោសុនខំ ឌុំសេចាន់ សាយស្សសោ ឆឌុំសេចា- ធំសុនខោ ចបណ្ឌិតោ ឆាលំកាដ្ឋតិ ។ ពាក្យពិត១បមា រីវ៉ាក្តសោតសា- ហាវហានអប្រិយ៍ ខឹងខាំបាទា អ្នកណាមួយក្តី អ្នកនោះទោះបី ខឹងដល់ប៉ុន្មាន ។ ពុំដែលខឹងប្រែ វិលខាំជើងវ៉ាក្ត វិញពុំដែលមាន នេះដូចអ្នកប្រាជ្ញ ឯងអាចញៀយញាណ ពុំដែលខឹងថ្កាន តបអ្នកពាលោ ។

---

១ លោកសំដៅយកអរិយទ្រព្យទាំង ៧ មានសទ្ធា, សីល ជាដើម ។

៤៤– ឃកបក្ខា មហាកជា ឃកកាមោ ទេវី មហន្តំ ឃកំយសោ ធានុវត្តយោ មហាសុខា ។ លោកជាមហាក្សត្រ សោយពផសម្បត្តិ រីករាស្ត្រផ្កា កុំមានហឫទ័យ អាល័យស្នេហា ស្រឡាញ់ករុណា តែអ្នកមួយឡើយ ។ រីកផជាយា អង្គអគ្គមហា មហេសីហើយ កុំមានចំណង់ ចិត្តចង់ច្រើនឡើយ ដ្បិតក្សត្រត្រាណត្រើយ ឥស្សូរសិរី ។ មួយសោតអ្នកណា មួយទឹងចង់ជា ឯកអគ្គមន្ត្រី កុំឲ្យសរសើរ ដំណើរតិតពី ស្រីសុខសួស្តី អង្គឯងប្រាកដ ។

ប្រិកបប្រុងប្រែ ស្រង់ស្រាយបានសែ សិចប្អូនជាបទ កាកកាព្យ
ដោយអាចិ ធារធម៌កំណត់ ទើបចង់ជាបទ ព្រហ្មគីតថា:

៤៥ – ធិធិធិរាបិ រដ្ឋំរាជិកា
ធារីរត្វា បរុក្ខាពធាលិ ។
រុក្ខាវិប្បតោ ចនសោភក្តេនិ
ចិរជេនុរិ សុភាសិតាកថា ។
លោកថារស្រះស្ងួត រឹងហែនហូតឥតគន្ធ
ទគតេតក្សត្រា ស្រីឥតស្បែងណ្តប់ប្រាណ ។
រីព្រសោតថាបើ មិនមានឈើដុះដោយដាន

(មានត)

ដំណឹងផ្សេងៗ

## ដំណឹងមួយក្នុងការសែតមហាពោធិ

ក្នុងការសែតមហាពោធិលេខប្រចាំខែយ៉ាំងវីយេរ ១៩៤០ នេះ យើងមានសេចក្តីត្រេកអរដោយបានឃើញផលប្រយោជន៍១ ដែលកើតអំពីជាងគំនូរ ជាស្នាដៃរបស់លោក តឺកា ដែលបានគូរដាក់កាតប៉ុស្តាល់ ស្រាប់តែបានឃើញគំនូរនេះគេយកទៅចុះបោះពុម្ពផ្សាយក្នុងការសែតមហាពោធិ ។ ឯគំនូរនេះគូរជារូបដំណាងកាលព្រះសម្មាសម្ពុទ្ធទៅថែរក្សាជម្ងឺព្រះបូតិគត្ត-តិស្សត្ថេរ ដូចយើងបានចុះផ្សាយក្នុងការសែតកម្ពុជសុរិយាលេខ ២ ឆ្នាំនេះរួចមកហើយ ។

ឯការសែតមហាពោធិនេះ ជាការសែតដ៏ថ្លៃថ្លា ១ ក្នុងលោកពុទ្ធសាសនា ដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស ហើយដាក់សុទ្ធតែរឿងល្អៗគួរចង់មើលចង់ស្តាប់ ។ ការសែតនេះមានមនុស្សមើលទូទៅទាំងស្រុកក្លិង្គ, ក្នុងលង្កា, ស្រុកភូមា, ស្រុកជប៉ុន, ស្រុកចិន, ទ្វីបអាមេរិក, ទ្វីបឧរុប នឹងស្រុកសៀមក៏មានមនុស្សត្រូវការមើលដែរ ។

យើងមានសេចក្តីត្រេកអរច្រើន ដែលបានឃើញសតិបញ្ញារបស់លោកតឺកា មានពុទ្ធសាសនិកជនជាន់ខ្ពស់ទទួលដឹងឮផងនេះ ។ យើងមានសង្ឃឹមថាអស់ទាំងជាងគំនូរធំៗដែលបានឃើញគំនូរផ្សេងៗ របស់លោក

តឹក គង់មានសេចក្ដីសរសើរដែរ ក្រែងតែពួកយើងដែលជាជនរួមជាតិជាមួយនឹងលោកតឹកនេះមិននឹកភ្នកសរសើរស្នាដៃដូចយើងបានពោលមកនេះៗ ។ អស់ទាំងរូបគំនូរល្អៗនឹងសៀវភៅមានបោះពុម្ពរូបប្រកបផងសុទ្ធតែជារបស់ល្អមើលទាំងអស់ ។ យើងមានជាងគំនូរដែលមានថ្វីដៃពូកែបែបនេះតិចណាស់ ដែលធ្វើឲ្យយើងជឿជាក់ថាស្រុកខ្មែរនេះមានមនុស្សជាច្រើនដែលមានការសិក្សាច្រើននឹងមានចំណេះច្រើនបានស្គាល់ស្រុកខ្មែរនេះទូទៅ ដោយសារជាងគំនូរម្នាក់នេះបានបញ្ចេញគំនិតដ៏ខ្ពង់ខ្ពស់នេះបង្ហាញឲ្យគេបានឃើញ ។

## វិជ្ជាវះកាត់របស់ឥណ្ឌា

នៅមហានគរបារាំងសែស មានបោះពុម្ពសៀវភៅ ១ និយាយពីវិជ្ជាពេទ្យ សុទ្ធតែពួកគ្រូពេទ្យបានតែងឡើង ជារឿងមានប្រយោជន៍ណាស់ យើងនឹងដកស្រង់យកត្រង់សេចក្ដីដែលមានប្រយោជន៍ដល់អ្នកមើលទស្សនាវដ្ដីរបស់យើង ក្នុងការព្រានតែងសេចក្ដីនេះ លោកគ្រូពេទ្យ ហ្វ័រគ៏ (Forque) បានតែងដំណាលរឿងនឹងសេចក្ដីដែលមានឡាក់ឋានតាមវិជ្ជាពេទ្យ លោកបានពោលពីប្រវត្តិរបស់គ្រូពេទ្យជីវក ជាគ្រូពេទ្យដែលមានចំណេះខាងវិជ្ជាវះកាត់យ៉ាងចំណាប់ដៃ លោកធ្លាប់ធ្វើមកក្នុងសម័យនោះ ។ លោកជីវកលះបង់កេរសម្បត្តិរបស់បិតា ដើម្បីរកសិក្សាខាងវិជ្ជាវះកាត់ ។

នៅប្រទេសឥណ្ឌាសម័យនោះ គេចេះវះកាត់ពេតភ្នែកបាំងស្បែក ឬភ្នែកបាយ ហើយនឹងវិជ្ជាវះកាត់ដែលជាវិជ្ជាទំនើបថ្មីនៅប្រទេសអឺរុប ដូចជាវិធីបណ្តុះផ្ចិតភ្ជាប់ត្រង់អវយវៈដែលខូចខាតទៅឲ្យគង់ទ្រង់ល្អឡើងវិញ នោះជាចំណេះដែលកើតឡើងមុនដំបូងបង្អស់នៅប្រទេសឥណ្ឌា ។ ឯវិធីវះកាត់យ៉ាងវិសេស ក៏មានពោលទុកក្នុងគម្ពីរជាន់ចាស់ដែលកើតឡើងជាដំបូង នឹងវិធីព្យាបាលជម្ងឺយ៉ាងវិសេសៗ ក៏មានសំដែងទុកដែរ ។

មានគម្ពីរពីរទៀត ក៏ចំណាប់ណាស់ដែរ ជាស្នាដៃរបស់លោក ចរកៈ ដែលបានតែងឡើងកាលពី ព.ស. ៥៤៣ នឹងគម្ពីររបស់លោក ស៊ុស្រុតៈ កាលពី ព.ស. ៩៤៣ ។

ក្នុងគម្ពីររបស់លោក ស៊ុស្រុតៈនោះ គេបានឃើញសេចក្តីថា "គ្រូពេទ្យណាដែលចេះត្រឹមវិធីព្យាបាលវិសេសតែមួយផ្លូវ ទុកដូចជាសត្វស្លាបដែលមានស្លាបតែមួយ" ហើយមានបន្ថែមសេចក្តីតទៅទៀតថា "សិស្សដែលចេះដឹងតែក្នុងគម្ពីរ ទុកដូចជាសត្វលាដែលគេផ្ទុកខ្លឹមចន្ទន៍នៅលើខ្នង បានតែធ្ងន់ ១ មុខ ឥតស្គាល់ដំឡៃឡើយ" ។ លោកស៊ុស្រុតៈ បានរៀបរៀងវិធីវះកាត់ ២១មុខ ប៉ុន្តែលោកពោលទុកក្នុងគម្ពីររបស់លោកថា "វិធីដែលវិសេសបំផុតស្រេចនៅលើដៃរបស់ សល្យពេទ្យ (ស្នាដៃរបស់គ្រូពេទ្យ)" ។

គេចាត់ចែងបង្ហាត់បង្រៀនពួកអ្នករៀនវះកាត់ឲ្យរៀនធ្វើពួកសត្វជាមុន លុះបើស្ទាត់ហើយទើបគេបង្រៀនឲ្យរៀនចៀរដើមឈើដើមថ្នាំជាបំរៀកល្អិតៗ ហើយគេច្រករបស់អស់នេះទៅក្នុងផ្តោកដែលពេញទៅដោយទឹក ឬស្រាសក់ ដើម្បីរៀបចំរៀនវិធីវះយកសរសៃខាងក្នុង ហើយគេបង្រៀនវិធីរុំសំពត់ទីងរូបគារមោង (ធ្វើជារូបធៀបនឹងមនុស្ស) ។

នៅក្នុងវគ្គមួយមាននិយាយថា លោកស៊ុស្រ៊ុត: រក្សាពេគប្តាក់ផ្អឹងដោយធ្វើព្រលមួស្សរុំអប សម្រាប់ជម្ងឺឈឺក្រពះនោម ថ្នាំផ្អឹងប្រជែសគ្នាពន្ធពោះវៀន (ចុកពោះ) វិធីកាត់វះពេគពកក ។ ឯការធ្វើឲ្យអ្នកជម្ងឺដេកលក់ក្នុងពេលដែលធ្វើការវះកាត់នោះ គេប្រើគ្រឿងថ្នាំដេកលក់ ។

លោកដុកទ័រ ស៊ុលបែរត៍មេឌិយោធី និងលោក ហ៊ុយបែរត៍ ស្វូស្សូផ បានពោលប្រវត្តិរឿងរ៉ាវរបស់កាមពេគទុកថា:

ជម្ងឺនេះកើតឡើងក្នុងប្រទេសបាកំងសែសនិងទ្វីបឥរុប កាលពី ព. ស. ១៩០០ គេបានសន្មតជាដើមកំណើតដែលជម្ងឺនេះបានកកើតឡើងជាដំបូងបង្អស់ ហើយគេបានជជែកជេញដោលគ្នាពីហេតុផលតាមសេចក្តីពិតមែន ប៉ុន្តែជម្ងឺនេះគេបានស្គាល់ច្បាស់តាំងពីសម័យព្រេងនាយនៅប្រទេសឥណ្ឌា ប្រទេសអេស៊ីប្តិ៍ ប្រទេសក្រិក និងប្រទេសចិនជប៉ុន សុទ្ធតែមានថ្នាំរក្សាពេគនេះមកហើយ គេបានពន្យល់អំពីជម្ងឺនេះសុទ្ធតែមានលក្ខណៈឃើញច្បាស់ថាជាជម្ងឺកាមពេគទាំងអស់ ។

(នេះហើយទើបគេហៅថា សន្សាបេក្រ មានទំនងដូចជាកន្សែងរ
តែនិយាលរលំផ្កាប់ផ្ការជាធម្មតា របស់ចាស់ឬវិជ្ជាជាន់ចាស់ តែបាត់បង់ទៅ
ជាយូរអង្វែងហើយមានអ្នកប្រាជ្ញរើរកឃើញឡើងវិញ គេសន្មតថាជា
របស់ទំនើបថ្មី កន្លងមកមិនទាន់បានប៉ុន្មានឆ្នាំ តែគេសន្មតថាជារបស់
ចាស់ទៅវិញ) ។

## អំពីបណ្ណាល័យក្នុងប្រទេសបារាំងសែស
## និងប្រទេសអង់គ្លេសនិងការមើលសៀវភៅ
## ក្នុងពេលដែលស្រុកមានសង្គ្រាម

បណ្ដាបណ្ណាល័យសំខាន់ៗនៃប្រទេសទាំងពីរនេះ នៅតែបើកឲ្យ
ប្រជាជនមើលសៀវភៅបានជានិច្ច ។ បណ្ណាល័យទាំងនេះ គេបានធ្វើ
គ្រឿងបង្ការគ្រាប់បែកនឹងភ្លើងឆេះ បណ្ដារបស់ល្អៗដែលមានដំឡៃ និង
បញ្ជីសៀវភៅផ្សេងៗ សុទ្ធតែមានគ្រឿងបង្ការយ៉ាងមាំមួនៗ នៅក្នុង
បណ្ណាល័យធំចំបងមួយនៃក្រុងឡុងដ៍ ប្រទេសអង់គ្លេស បណ្ដាអ្នកមើល
សៀវភៅគោងតែពាក់ប្រដាប់បង្ការផ្សែងពុលយ៉ាងប្រញាប់ ប្រសិនបើ
មានអាណត្តិសញ្ញាប្រាប់ឲ្យដឹងខ្លួនឡើង សុទ្ធតែមានគ្រឿងបង្ការខ្លួន
ដោយឡែក សម្រាប់ពួកអ្នកមើលសៀវភៅអស់នោះ ។

ក្រុងប៉ារីស នៅក្នុងបណ្ណាល័យធំចំបងមួយនោះ គេបានរៀបចំទីកន្លែង ១ នៅក្នុងដី ជាកន្លែងសម្រាប់មើលសៀវភៅ ក្នុងពេលដែលស្រុកទេសមានចំបាំង ៗ ក្នុងបណ្ណាល័យខ្លះក្រសួងឲ្យខ្ចីសៀវភៅគោងតែរៀបចំជាថ្មីក៏មាន ៗ នៅបណ្ណាល័យដទៃទៀតជាច្រើន គេបានកសាងសម្រាប់បង្ការគ្រោះទ័ព ដោយធ្វើបន្ទាយទាហាន ទាំងសម្រាប់ពួកមនុស្សដែលផ្លាស់ពីខេត្តក្រៅអាស្រ័យនៅបាន ហេតុនេះបានជាគេឃើញច្បាស់ថាប្រទេសអង់គ្លេសនឹងប្រទេសបារាំងសែស ប្រកាន់ការមើលសៀវភៅជារបស់សំខាន់នឹងមានផលប្រយោជន៍ទុកដូចជាការតតាំងនឹងសត្រូវ ជាកិច្ចខានធ្វើពុំបាន ទាំងការជួយថែរក្សាគម្ពីរគតិជំបរិ-សុទ្ធទុក ៗ ក្នុងកញ្ចប់គ្រប់ ៗ កញ្ចប់ដែលគេបញ្ជូនទៅឲ្យទាហានដែលច្បាំងគ្នានោះ តែងមានសៀវភៅ ១ ជានិច្ច ហើយនៅប្រទេសអង់គ្លេសគេបម្រុងនឹងរៀបចំក្រសួងឲ្យខ្ចីនេះ ដោយវិធីធ្វើឲ្យជាទីគាប់ចិត្តដល់អ្នកសុំខ្ចីទាំងអស់គ្នាតាមត្រូវការ ៗ

## ទស្សនាវដ្ដីពុទ្ធចិន្តា

ក្នុងទស្សនាវដ្ដីបារាំងសែស ១ ហៅថា "ពុទ្ធចិន្តា" ( La pensée Bouddhique ) ដែលយើងទើបនឹងបានទទួលនេះ មានសេចក្ដីមួយល្មមយល់បានថាជាសេចក្ដីតែងល្អគួរឲ្យចង់ដឹង គឺមានសេចក្ដីមួយនិយាយ

ពីសមាធិឬឈានរបស់ព្រះពុទ្ធ ជាសេចក្តីប្រែពីមហាសតិបដ្ឋានសូត្រ (ទីឃនិកាយ) មកជាភាសាបារាំងសែស ហើយមានរឿងសង្ខេបមួយ និយាយពីបាឋកថារបស់ម៉ាដាមដាវីត់នីល ដែលគាត់បានសំដែងក្នុងប្រទេសចិន បាឋកថានេះនិយាយអំពីពុទ្ធសាសនានៅប្រទេសទីបេត៍ ហើយមានរឿងមួយជាសេចក្តីបង្ហើយខាងចុងនោះ និយាយពីបែបផែនទ្រង់ទ្រាយព្រះស្តូប ។

រួចមានសេចក្តីអធិប្បាយមួយដែលជនជាតិបារាំងសែសបង្ហាញឲ្យឃើញគំនិតយោបល់អំពីលទ្ធិពុទ្ធសាសនា ទុកជាដំណើរថ្មីមួយនៅក្នុងលោកពុទ្ធសាសនា នៅមាន២រឿងទៀតជាសេចក្តីសារស័ព្ទពីគុណ-សម្បត្តិរបស់អ្នកដែលមានកេរ្តិ៍ឈ្មោះដែលអនិច្ចកម្មទៅ គឺរឿងមួយនិយាយពីលោក គុតដារត៍ ជាតិអាមេរិកាំង ដែលបានធ្វើដំណើរទៅប្រទេសចិនក្នុងគណៈអ្នកដើរប្រកាសសាសនាគ្រិស្ត ។

# រឿងព្រេងខ្មែរ — រឿងអាឡេវ (ទី ២)

(តមក)

បញ្ឆោតចោរទាំង៥០០នោះថា វីអាគមខ្ញុំនេះ ដែលនឹងរៀននោះ ត្រូវមុជទឹកហើយទឹកសូត្រអត់ដង្ហើមនៅក្នុងទឹកបាន ៧ ចប់ទើបពូកែ ៗ ពួកចោរក៏នាំគ្នាហាត់មុជទឹកសូត្រអាគម ៗ ឯអាឡេវចុះទៅសំពៅ និយាយខ្សឹបប្រាប់ប្រពន្ធឲ្យរៀបខ្លួនហើយទាញពួរយុថ្កាឲ្យខ្ញុំ ក៏ផ្តាំប្រពន្ធថា បើអញរត់ចុះមកពីលើគោកត្រូវទាញពួរយុថ្កាឡើងជាដាច់ ផ្តាំស្រេចហើយក៏ត្រឡប់ទៅវិញ លុះដល់ពេលយប់ងងឹតក៏ឲ្យពួកចោរមុជទឹកហើយបង្គាប់ថាបើមុជត្រូវមុជឲ្យព្រមគ្នា បើងើបៗឲ្យព្រមគ្នាទើបអាគមពូកែ ៗ លុះពួកចោរមុជព្រមគ្នាហើយ អាឡេវក៏រត់ចុះទៅសំពៅ ដកយុថ្កាលាក្តោង ជូនជាខ្យល់ដំនោរមកដល់ អាឡេវបើកក្តោងយោងទាំងសំប៉ានទៅចោលចោរទាំង៥០០នៅលើកោះនោះ ៗ ឯចោរទាំង៥០០ងើបអំពីទឹកឡើង រកមើលអាឡេវមិនឃើញ ក៏សួរគ្នាថា លោកគ្រូទៅណាហើយនាំគ្នារកក្នុងរោងពិធីមិនឃើញ ទើបចុះទៅមើលឯកំពង់ក៏មិនឃើញបាត់ទាំងសំពៅ ពួកចោរទាំង ៥០០ ក៏ដឹងថាអាឡេវបញ្ឆោតហើយទើបនាំគ្នារកឈើឫស្សីធ្វើក្បូនឆ្លង ៗ

ឯអាឡេវក៏បើកសំពៅយកទ្រព្យរបស់ចោរទាំង ៥០០ ដែលនៅក្នុងសំពៅនោះទៅតែពីរនាក់ប្តីនឹងប្រពន្ធ លុះបើកក្តោងទៅអស់មួយយប់

មួយថ្ងៃក៏បានដល់ទៅស្រុកមួយ ហើយក៏គេមើលមនុស្សក្នុងស្រុកនោះ ពុំឃើញមានមនុស្សប្រុស មានតែស្រី ទើបដឹងថាជាស្រុកចោរដែលគេបញ្ឆោតនោះ ហើយក៏បោះយុថ្កាឈប់ ។ ឯអស់ប្រពន្ធចោរទាំងនោះ នឹងបានដឹងស្គាល់ថាជាសំពៅរបស់ប្ដីក៏ទេ ដ្បិតកាលដែលប្ដីចេញទៅអំពីផ្ទះតែខ្លួនទទេ លុះបានជួបនឹងសំពៅឈ្មួញក៏ប្លន់យក បានជាប្រពន្ធកូនមិនដឹងមិនស្គាល់ ។ លុះអាឡេវបោះយុថ្ការួចស្រេចហើយ ក៏យកដីសនឹងក្ដារឆ្នួនចេញមកក្រៅហើយគូរក់សចាប់យាម ។ ឯអស់ប្រពន្ធកូនចោរមើលមកឃើញអាឡេវគូរក់សដូច្នោះ ក៏នឹកស្មានថាគេចេះចាប់យាម ទើបសួរថា អ្នកអើយ អ្នកចេះចាប់យាម អាណិតមើលឲ្យប្ដីយើងខ្ញុំបន្តិច ដ្បិតគាត់ទៅរកស៊ីជាយូរខែហើយ ។ អាឡេវឮដូច្នោះហើយក៏ដឹងថាស្រីទាំងនេះជាប្រពន្ធចោរដែលអញបញ្ឆោតនោះប្រាកដ ហើយក៏ឆ្លើយឡើងថាក្រអឺសព្វបើចាប់យាមនោះ ទោះបីមើលសម្ពង្សសម្ភារក្ដី អត្តៈ លេខ យ័ន្តអ៊ីខ្ញុំក៏ចេះទាំងអស់ អ្នកចង់មើលអំពីរឿងអ្វីយកតែទៀនធូបស្លាម្លូមកបូជាគ្រូ កុំឲ្យសាបអាគមយាមខ្ញុំ តាមគ្រូប្រដៅផ្ដាំមក ។ ឯប្រពន្ធចោរឮអាឡេវថាដូច្នោះ ក៏ម្នីម្នាឡើងទៅផ្ទះជាប្រញាប់ ប្រាប់ប្រពន្ធចោរឯទៀតៗឲ្យរកទៀន ធូប ក្រ ផ្កា ស្លា ម្លូ ចេក អំពៅ យកទៅជូនគ្រូ ។ អាឡេវទទួលយកជំនូនហើយ តាំងយកក្ដារឆ្នួនមកគូរក់ស

ធ្វើជាចាប់យាម គិតប្រមាណក្នុងចិត្តឲ្យត្រូវពេលាល្មមពួកចោរទាំង៤០០ នោះមកដល់ផ្ទះ គឺវាគិតប្រមាណគ្នេរចំងាយផ្លូវហើយប្រាប់ប្រពន្ធចោរ ថា ប្ដីអស់អ្នកកាល់គ្នានឹងមកដល់ចាប់ក្នុងថ្ងៃស្អែកនេះ ប៉ុន្តែក្នុងវេលាយប់ នេះនឹងមានព្រាយក្បាលត្រងោល ស្រាតសំពត់រត់ចូលមកក្នុងផ្ទះបង្កើត ជាឧត្បាទ៍ធំណាស់ បើដូច្នេះមានតែអ្នកកាល់គ្នាគិតរំងាប់ឧត្បាទ៍ចេញ ទើបជា ៗ ឯអស់ប្រពន្ធកូនចោរទាំង ៤០០ ឮអាឡេវថាដូច្នោះក៏ភិតភ័យ ហើយសួរថា គិតធ្វើដូចម្ដេចនឹងរំងាប់ឧត្បាទ៍ចេញបាន ។ អាឡេវឆ្លើយ ឡើងថា វាងាយទេការរំងាប់ឧត្បាទ៍នោះ គឺដល់វេលាព្រលប់កាលណា ត្រូវអស់អ្នកកាល់គ្នានាំកូនទៅកាន់ដំបងព្រនង់ទៅចាំនៅមាត់ទ្វារផ្ទះ បើ ឃើញព្រាយក្បាលត្រងោលហើយអាក្រាតសំពត់រត់ចូលមកក្នុងផ្ទះ ត្រូវ វាយកុំឲ្យចូលទៅបាន ។ ឯពួកចោរទាំង ៤០០ លុះឆ្លងរួចដល់ត្រើយ កាលណា ពេលាថ្ងៃពួនព្រៃ យប់នាំគ្នាដើរកាត់តម្រង់មកផ្ទះ ព្រោះគ្មាន សំពត់ស្លៀកបានជាមិនចេញដើរពេលថ្ងៃ ៗ លុះដល់ថ្ងៃកំណត់ដែលអា ឡេវចាប់យាម ក្នុងពេលព្រលប់ពួកចោរក៏មកដល់ផ្ទះខ្លួន ៗ

(មានត)